**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
* * * * * *

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
* * * * * *

# ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ជំរុញកិច្ចសហប្រតិបត្តិការកម្ពុជា-ឡាវ

* * * * * *

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានគូសបញ្ជាក់អំពីទំនាក់ទំនងដ៏ជិតស្និទ្ធរវាងប្រទេសទាំងពីរកម្ពុជា-ឡាវ ក្រោមស្មារតីភាពជាអ្នកជិតខាងល្អ សាមគ្គីភាពជាភាតរៈ និងភាពជាដៃគូយុទ្ធសាស្ត្រយូរអង្វែង និងគ្រប់ជ្រុងជ្រោយ ហើយបានលើកទឹកចិត្តឱ្យជំរុញបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការល្អប្រសើរលើគ្រប់វិស័យ រួមមាន ពាណិជ្ជកម្ម វិនិយោគ អប់រំ ទេសចរណ៍ ការតភ្ជាប់ និងទំនាក់ទំនងរវាងប្រជាជននិងប្រជាជន ក្នុងឱកាសដែល **ឯកឧត្តម បួរកែវ ភូមិវង្សសៃ** ឯកអគ្គរដ្ឋទូតថ្មីឡាវប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នាព្រឹកថ្ងៃទី ២២ ខែមេសា ឆ្នាំ២០២២។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានរំលឹកឡើងវិញអំពីការប្រារព្ធខួបអនុស្សាវរីយ៍លើកទី៦៥ នៃការបង្កើតទំនាក់ទំនងការទូត កាលពីឆ្នាំ២០២១ និងដំណើរទស្សនកិច្ចផ្លូវការប្រកបដោយជោគជ័យរបស់ **ឯកឧត្តមនាយករដ្ឋមន្ត្រីឡាវ ផនខាំ វីផាវ៉ាន់** និង**ឯកឧត្តមរដ្ឋមន្ត្រីការបរទេស សាលើមសៃ គុំម៉ាស៊ីត** មកកាន់កម្ពុជា នាពេលកន្លងមក ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងការលើកស្ទួយទំនាក់ទំនងទ្វេភាគី។

ឯកឧត្តមឯកអគ្គរដ្ឋទូត បានពាំនាំនូវការថ្លែងអំណរគុណដ៏ជ្រាលជ្រៅរបស់រដ្ឋាភិបាល និងប្រជាជនឡាវ ជូនចំពោះរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ដែលបានផ្តល់វ៉ាក់សាំងចំនួន៧00.000 ដូស សម្ភារៈពេទ្យ រថយន្ត និងថវិកា សម្រាប់ការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។ ឯកឧត្តមឯកអគ្គរដ្ឋទូត ក៏បានវាយតម្លៃខ្ពស់ចំពោះការខិតខំរបស់កម្ពុជាក្នុងនាមជាប្រធានអាស៊ាន ក្នុងការស្វែងរកដំណោះស្រាយចំពោះវិបត្តិនៅមីយ៉ាន់ម៉ា និងបានគូសបញ្ជាក់ពីការគាំទ្ររបស់ឡាវចំពោះការខិតខំនេះ។

ចំពោះកិច្ចការព្រំដែន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានលើកទឹកចិត្តឲ្យគណៈកម្មការចម្រុះកិច្ចការព្រំដែន (JBC) ទាំងពីរ ពន្លឿនការចរចារដើម្បីដោះស្រាយខ្សែព្រំដែនពុំទាន់ខណ្ឌសីមា ដែលនៅសេសសល់ចំនួន ១៤% តាមការឯកភាពរវាងថ្នាក់ដឹកនាំប្រទេសទាំងពីរ កាលពីខែវិច្ឆិកា ឆ្នាំ

២០២១ ហើយនិងការពិភាក្សាលើសេចក្ដីព្រាងសន្ធិសញ្ញាកំណត់ព្រំដែនរវាងប្រទេសទាំងពីរចំពោះខ្សែបន្ទាត់ព្រំដែនដែលបានឯកភាពគ្នារួចហើយចំនួន ៨៦%។

ឯកឧត្ដម ឧបនាយករដ្ឋមន្ត្រី និងឯកឧត្ដម ឯកអគ្គរដ្ឋទូត ក៏បានពិភាក្សាគ្នាអំពីការត្រៀមរៀបចំកិច្ចប្រជុំរបស់គណៈកម្មការចម្រុះកម្ពុជា-ឡាវ ស្ដីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (JCBC) ដែលគ្រោងធ្វើនៅរាជធានីភ្នំពេញ ក្នុងខែកក្កដា ខាងមុខនេះ។

**ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី** និង **ឯកឧត្ដមឯកអគ្គរដ្ឋទូត** ក៏បានពិភាក្សាផងដែរ អំពីបញ្ហាតំបន់ និងអន្តរជាតិសំខាន់ៗ រួមទាំងកិច្ចសហប្រតិបត្តិការនៅក្នុងក្របខ័ណ្ឌ អាស៊ាន និងអង្គការអន្តរជាតិនានា៕

-------------------------